| ៥៨ | មាន់ ផាត | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៥៩ | យ៉ែម អុន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦០ | ងួន អេង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦១ | ចែ ខេម | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦២ | សែម ឡឹង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៣ | សេត ង៉ាន់ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៤ | ថន ជីវ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៥ | កែវ តេងហ៊ុយ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៦ | គៀ ចន្ទដារា | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៧ | ប៉ុច សុខលៀង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៨ | ហួន ឡៃ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៦៩ | ញ៉ៀន គ្រួក | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧០ | សឿង ស្រៀន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧១ | អ៊ុម ណែម | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧២ | ស្រេង ឈុនលី | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៣ | អ៊ុម មឿន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៤ | ម៉ីយ ទូច | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៥ | ស៊ុយ ហាន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៦ | វ៉ាន ភឿក | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៧ | មៅ ទូច | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៧៨ | ដៃ ភ័ស | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |

| | | | | |
|---|---|---|---|---|
| ៧៩ | ឈួន ស្រស់ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨០ | អ៊ីន ស្រស់ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨១ | ណយ នាង | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨២ | ឈួន ឈើន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៣ | សុន យ៉េម | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៤ | ទន់ ខឿន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៥ | វ៉ៃន កុល | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៦ | ឡូច ណេង | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៧ | យ៉ែម យ៉ាន់ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៨ | ចាន់ ខឿក | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៨៩ | ស៊ី រីន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩០ | ស៊ុក ង៉ែត | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩១ | កែវ គឿន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩២ | អ៊ុក ធុំ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៣ | ផែង ណន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៤ | ផុន វៃ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៥ | ឡូច ណេង | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៦ | ងួន ហួត | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៧ | គង ភ៉ាត់ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៨ | សេត អួក | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ៩៩ | អ៊ី យន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០០ | អ៊ីម ម៉ុន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០១ | ព្រឹង ជើង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០២ | អ៊ិន សំអាង | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០៣ | គង ជា | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០៤ | ណៃ ធឿន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០៥ | ហួត សុខ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០៦ | ស៊ ុន ស្រស់ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |

| | | | | |
|---|---|---|---|---|
| ១០៦ | ស៊្រុន ស្រស់ | ប្រុស | កសិករ | ២០/០៤/០៨ |
| ១០៧ | សេង រ៉ុង | ប្រុស | កសិករ | ២០/០៤/០៨ |
| ១០៨ | ស៊ុ ជើង | ស្រី | កសិករ | ២០/០៤/០៨ |
| ១០៩ | ជា សុផាត | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១០ | កែវ ចេក | ស្រី | កសិករ | ២០/០៤/០៨ |
| ១១១ | ស៊ុក ទៀង | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១២ | កែវ កាន | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១៣ | ស៊ុក សុខចាន់ | ស្រី | កសិករ | ២០/០៤/០៨ |
| ១១៤ | ចិន វិុច | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១៥ | ឯក សុខលី | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១៦ | សុន ផាន | ប្រុស | កសិករ | ២០/០៤/០៨ |
| ១១៧ | ចាន់ សាវ | ស្រី | កសិករ | ២០/០៤/០៨ |
| ១១៨ | ស៊ុ ហួយ | ស្រី | កសិករ | ២០/០៤/០៨ |
| ១១៩ | អឹម កែវ | ប្រុស | កសិករ | ២០/០៤/០៨ |
| ១២០ | តុប លឹម | ប្រុស | កសិករ | ២០/០៤/០៨ |
| ១២១ | ស៊ិន ស៊ីម | ប្រុស | កសិករ | ២០/០៤/០៨ |
| សរុបរួម ១២១ នាក់(ស្ត្រី ៧០ នាក់) | | | | |

ចំប៊ី ថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ ២០០៨

បានឃើញ និងឯកភាព

មេឃុំចំប៊ី

ចំប៊ី ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០៨

ប្រធានគណៈកម្មការសហព័ន្ធ

សហគមន៍នេសាទចំប៊ី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ ភូមិជើងលោង**

**ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ**

| ល.រ | នាម និងគោត្តនាម | ភេទ | មុខរបរ | ថ្ងៃ ខែ ឆ្នាំ ចូលជាសមាជិក |
|---|---|---|---|---|
| ០១ | ស៊្រុន មៅ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០២ | ជុត ភាន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៣ | ឆុំ វ៉ាត | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៤ | យុម សារ៉ែម | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៥ | ប៊ូ យ៉ាន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៦ | ទូច ណាន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៧ | វ៉ែន ប៊ិច | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៨ | វ៉ែន ញឹប | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ០៩ | សិច ធីម | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១០ | រ៉ែន ឡេង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១១ | ទ្រី សារុំ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១២ | វុធ សារុំ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៣ | ជៀប ធឿន | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៤ | តន គីមសៀង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៥ | ស៊ិន លាន | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៦ | សាន ឡៃ | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៧ | កែប អេង | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៨ | លុន ម | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ១៩ | ប៉ាង ធី | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ២០ | មៅ យ៉ាន់ | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ២១ | ក្រុត ប៉ាច | ប្រុស | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |
| ២២ | ប៉ា ប៊ិច | ស្រី | ធ្វើស្រែ-នេសាទ | ២០ /០៤ / ២០០៦ |

| | | | | |
|---|---|---|---|---|
| ២២ | ប៉ា ប៊ិច | ស្រី | កសិករ | ២០/០៤/០៨ |
| ២៣ | ជុក រឿន | ប្រុស | កសិករ | ២០/០៤/០៨ |
| ២៤ | ហ៊ួ ប៉ាវ | ស្រី | កសិករ | ២០/០៤/០៨ |
| ២៥ | ទឹក ស្រី | ប្រុស | កសិករ | ២០/០៤/០៨ |
| ២៦ | ស៊ៀ យឹម | ស្រី | កសិករ | ២០/០៤/០៨ |
| ២៧ | គួក លាងអ៊ី | ប្រុស | កសិករ | ២០/០៤/០៨ |
| ២៨ | ថា ស្រី | ស្រី | កសិករ | ២០/០៤/០៨ |
| ២៩ | ហ៊ុន ផល | ស្រី | កសិករ | ២០/០៤/០៨ |
| ៣០ | វ៉ាន ផល្លី | ស្រី | កសិករ | ២០/០៤/០៨ |
| ៣១ | នួន រស់ | ស្រី | កសិករ | ២០/០៤/០៨ |
| ៣២ | ប្រុស ហៀក | ប្រុស | កសិករ | ២០/០៤/០៨ |
| ៣៣ | វុន មៅ | ស្រី | កសិករ | ២០/០៤/០៨ |
| ៣៤ | ភី ថុល | ស្រី | កសិករ | ២០/០៤/០៨ |
| ៣៥ | ហ៊ាន សុន | ប្រុស | កសិករ | ២០/០៤/០៨ |
| ៣៦ | មិច រ៉ា | ស្រី | កសិករ | ២០/០៤/០៨ |
| ៣៧ | ពិជ ណួយ | ប្រុស | កសិករ | ២០/០៤/០៨ |
| ៣៨ | បាន រី | ស្រី | កសិករ | ២០/០៤/០៨ |
| ៣៩ | ពៅ ផាត | ស្រី | កសិករ | ២០/០៤/០៨ |
| ៤០ | ស៊ីម បាវ | ស្រី | កសិករ | ២០/០៤/០៨ |
| ៤១ | ហុង រឿន | ស្រី | កសិករ | ២០/០៤/០៨ |
| ៤២ | ហួត ហៃ | ប្រុស | កសិករ | ២០/០៤/០៨ |
| សរុបរួម ៤២ នាក់(ស្ត្រី ៣១ នាក់) | | | | |

ចំប៉ី ថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ ២០០៨

**បានឃើញ និងឯកភាព**

**មេឃុំចំប៉ី**

ចំប៉ី ថ្ងៃទី 3 ខែ ឧសភា ឆ្នាំ ២០០៨

**ប្រធានគណៈកម្មការសហគំនូ**

**សហគមន៍នេសាទចំប៉ី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហព័ន្ធសហគមន៍នេសាទ
# ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ហែម ធឿង | ប្រុស | ប្រធានគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០២ | លោក សេង ស៊ីវុត្ថា | ប្រុស | អនុប្រធានគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០៣ | លោក ដួត ដួង | ប្រុស | អនុប្រធានគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០៤ | លោក ស៊ឹម ហៃ | ប្រុស | សមាជិកគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០៥ | លោក ព្រឿង ចាន់រឿង | ប្រុស | សមាជិកគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០៦ | អ្នកស្រី ថ្លាង ហុង | ស្រី | សមាជិកគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |
| ០៧ | អ្នកស្រី ហ៊ិន សារ៉េន | ស្រី | សមាជិកគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ |

ចំប៉ី ថ្ងៃទី ០៦ ខែ ០៩ ឆ្នាំ២០០៨

បានឃើញ និងឯកភាព

មេឃុំចំប៉ី

ចំប៉ី ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០០៨

ប្រធានគណៈកម្មការសហព័ន្ធ

សហគមន៍នេសាទចំប៉ី

ហែម ធឿង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ

# ភូមិបឿងប្រចិន ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ម៉ឹយ អៀក | ប្រុស | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០២ | លោក ប៉ូច លេន | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៣ | លោក ធី ឃៀង | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៤ | លោក លន់ កៅ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៥ | លោក អោ លី | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |

ចំប៉ី ថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ២០០៨

**បានឃើញ និងឯកភាព**

**មេឃុំចំប៉ី**

ចំប៉ី ថ្ងៃទី [illegible] ខែ [illegible] ឧសភា ឆ្នាំ២០០៨

**ប្រធានគណៈកម្មការសហព័ន្ធ**

**សហគមន៍នេសាទចំប៉ី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ
# ភូមិថ្នាក់ ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ហែម ធឿង | ប្រុស | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០២ | លោក សេន វណ្ណា | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៣ | លោក អុន ខុន | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៤ | លោក ឆិល ពៅ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៥ | លោក ជន រិក | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |

ចំប៉ី ថ្ងៃទី ៦ ខែ ៥ ឆ្នាំ ២០០៨
បានឃើញ និងឯកភាព
មេឃុំចំប៉ី

ចំប៉ី ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០៨
ប្រធានគណៈកម្មការសហព័ន្ធ
សហគមន៍នេសាទចំប៉ី

ហែម ធឿង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ
# ភូមិដើមដូង ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ឆន ឌី | ប្រុស | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០២ | លោក គយ បូរ | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៣ | លោក មាស សំអាន | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៤ | លោក ទូន ឡាយ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៥ | លោក សុខ វៃ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |

ចំប៉ី ថ្ងៃទី ៤ ខែ 5 ឆ្នាំ ២០០៨

បានឃើញ និងឯកភាព

មេឃុំចំប៉ី

ចំប៉ី ថ្ងៃទី 3 ខែ ឧសភា ឆ្នាំ ២០០៨

ប្រធានគណៈកម្មការសហគមន៍

សហគមន៍នេសាទចំប៉ី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ

## ភូមិជើងលោង ឃុំចំប៉ី ស្រុកបានី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ម៉ុក ពេជ្រ | ប្រុស | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០២ | លោក ជួន បាន | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៣ | លោក សួន ជាប | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៤ | លោក សៀង ឡុញ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៥ | លោក ជា ខ្លឹង | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ (បេឡា) |

ចំប៉ី ថ្ងៃទី ០៦ ខែ ០៩ ឆ្នាំ២០០៨

**បានឃើញ និងឯកភាព**

**មេឃុំចំប៉ី**

ចំប៉ី ថ្ងៃទី ៦ ខែ [illegible] ឆ្នាំ២០០៨

**ប្រធានគណៈកម្មការសហព័ន្ធ**

**សហគមន៍នេសាទចំប៉ី**

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ
# ភូមិព្រៃមូល ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

| ល.រ | នាម និង គោត្តនាម | ភេទ | មុខងារ |
|---|---|---|---|
| ០១ | លោក ផុំ ស្រេង | ប្រុស | ប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០២ | លោក មៃ នាង | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៣ | លោក អៀង សេង | ប្រុស | អនុប្រធានគណៈកម្មការសហគមន៍នេសាទ |
| ០៤ | លោក សូត្រ សឿន | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |
| ០៥ | លោក ប៉ាច មៅ | ប្រុស | សមាជិកគណៈកម្មការសហគមន៍នេសាទ |

ចំប៉ី ថ្ងៃទី ០៦ ខែ ០៥ ឆ្នាំ២០០៨

បានឃើញ និងឯកភាព

មេឃុំចំប៉ី

ពាន់ ថៃ

ចំប៉ី ថ្ងៃទី ៣ ខែ ៧ សីហា ឆ្នាំ២០០៨

ប្រធានគណៈកម្មការសហព័ន្ធ

សហគមន៍នេសាទចំប៉ី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៤-លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ ចំប៉ី

ភូមិ ៖ ម្កាក់(ទំនប់សំពោច)

ឃុំ ៖ ចំប៉ី

ស្រុក ៖ បាទី

ខេត្ត ៖ តាកែវ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៛៙៛៚

# លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
# សហព័ន្ធ សហគមន៍នេសាទចំប៉ី

## ភូមិ ម្កាក់ (ទំនប់សំពោច) ឃុំចំប៉ី
## ស្រុកបាទី ខេត្តតាកែវ

បានប្រជុំឆ្លងគណៈកម្មការ សហព័ន្ធ សហគមន៍នេសាទចំប៉ី

គណៈកម្មការសហគមន៍នេសាទភូមិ ជើងលោង,ព្រៃមូល,មឿងប្រចិន,ម្កាក់ និងដើមដូង

ថ្ងៃទី ១៧-១៨ ខែ មិថុនា ឆ្នាំ ២០០៦

## គំរូលក្ខន្តិកៈសហគមន៍នេសាទ

## ជំពូកទី ១

## គោលបំណង និងនាមករណ៍

**ប្រការ ១:** លក្ខន្តិកៈនេះមានគោលបំណង÷

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ ការប្រើប្រាស់ធនធានជលផល ប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទសាមុី
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ។

**ប្រការ ២:** សហគមន៍នេសាទឈ្មោះ **សហព័ន្ធសហគមន៍នេសាទចំប៉ី**

ហៅកាត់ថា **ស.ស.ន.ច.ប**

អាសយដ្ឋានភូមិ **ម្កាក់( ទំនប់សំពោច)** ឃុំ **ចំប៉ី** ស្រុក **បាទី** ខេត្ត **តាកែវ**

សហព័ន្ធ សហគមន៍នេសាទចំប៉ី មានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុងភូមិដូចខាងក្រោមៈ

១-ភូមិជើងលោង ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

២-ភូមិ ព្រៃមូល ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

៣-ភូមិ មឿងប្រចិន ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

៤-ភូមិ ម្កាក់ ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

៥-ភូមិ ដើមដូង ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

មានកម្មវត្ថុ **អភិវឌ្ឍន៍ដែននេសាទសហគមន៍**

## ជំពូកទី ២

## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣ :** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានលំនៅដ្ឋាននៅក្នុង ឬក្បែរកន្លែងនេសាទសហគមន៍មានសិទ្ធិចូលជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្តតាមរយៈការដាក់ពាក្យសុំ។

អ្នកដែលមានបំណងចង់ចូលជាសមាជិក សហគមន៍នេសាទ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើង។

**ប្រការ ៤:** សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើ មានសិទ្ធិ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ

និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ

- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ។
- សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរៀង១ខ្លួន និងរួមគ្នាផងចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ចដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមីហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី (៣) នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទ នូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ។

**ប្រការ ៥:** សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ៨០ អនក្រ.បកចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗ ទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន **១០០០** រៀល តាមការសម្រេចរបស់មហាសន្និបាត ពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន **៥០០**រៀល តាមការសម្រេចតាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើលទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦:** ចំពោះអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទមិនបានគោរពតាមប្រការនេះគណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ។

## ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្ដេញចេញពីសមាជិក

**ប្រការ ៧:** សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

## ជំពូកទី ៤

## របៀបរបបកាន់បញ្ជី និងឯកសារនានា

**ប្រការ ៨:** ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ៩:** រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ÷

-ការចំណាយពី ៥០០០ រៀល ដល់ ៣០០០០ រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ

-ការចំណាយពី ៣៥០០០ រៀល ដល់១០០០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ ។

-ការចំណាយពី ១០០០០០ រៀល ដល់ ១៥០០០០រៀល ត្រូវសម្រេចដោយមហាសន្និបាត (២/៣) ។

**ប្រការ ១០:** សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី÷

- ចំណូល ចំណាយថវិកា
- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ

-ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

**ប្រការ ១១:** ការគ្រប់គ្រង និងប្រើប្រាស់ថវិកា÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ។

## ជំពូកទី ៥
## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២:** សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយ រូប និងត្រូវមានការពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងៗទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន។

**ប្រការ ១៣:** គណៈកម្មការសហគមន៍នេសាទមានអណត្តិប្រាំ (៥) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីសហគមន៍នេសាទដំណើរការមិនប្រក្រតីដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី។

**ប្រការ ១៤:** ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាមួយអវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ (៦) ខែ ឬសុំលាលែងមុនចប់អណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

## ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥:** គណៈកម្មការសហព័ន្ធ សហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែនៅថ្ងៃទី ១៥ ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការសហគមន៍នេសាទទាំងមូល។

**ប្រការ ១៦:** ប្រធានគណៈកម្មការសហព័ន្ធ សហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហព័ន្ធសហគមន៍នេសាទអវត្តមាន អនុប្រធានដែលបានការប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧:** ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍នេសាទដូចមានចែងខាងក្រោមនេះ គឺត្រូវបានអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកសហគមន៍នេសាទថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិក សហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨:** មហាសន្និបាតសហគមន៍នេសាទជាអង្គការកំពូល ដើម្បីអនុម័ត និងធ្វើសេចក្តី សម្រេចទាំងឡាយក្នុង

នាមសហគមន៍នេសាទ ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានការជួយសម្របសម្រួលពីរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ។
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ។

**ប្រការ ១៩:** មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ។ ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច ។

**ប្រការ ២០:** គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយស ក្នុងមហាសន្និបាតសហគមន៍នេសាទ ។

**ប្រការ ២១:** លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ សង្កាត់និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទ ឱ្យចូលរួមមហាសន្និបាតសាមញ្ញ ត្រូវធ្វើឡើងដប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ ។
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ អាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ ។
- អង្គប្រជុំមហាសន្និបាត ដឹកនាំដោយប្រធានគណៈកម្មការសហព័ន្ធ សហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាធិការអង្គប្រជុំ ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន

- លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

**ប្រការ ២២:** មហាសន្និបាតអនុម័ត÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣:** ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះ ត្រូវអនុម័តដោយមហាសន្និបាត។

**ប្រការ ២៤:** កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី (៣) ទៅប្រាំ (៥) នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

**ប្រការ ២៥:** គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីប្រកាសជូនមហាសន្និបាត ។
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ។

**ប្រការ ២៦:** បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការ

សហគមន៍នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើស ស្ត្រី ឬ បោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាដែលចូលរួម ។

## ជំពូកទី ៩

## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧:** ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។
- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តរបស់សហគមន៍ត្រូវអនុម័តតាមមហាសន្និបាតលើកលែងតែដែននេសាទត្រូវប្រគល់ឱ្យរដ្ឋវិញ ។

**ប្រការ ២៨:** ក្នុងករណីមានការតវ៉ាចោទប្រកាន់ថាដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាមនៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩:** វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម÷

- គណៈកម្មការសហគមន៍នេសាទមានសិទ្ធិសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចជំនាញដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។
- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាកាខេត្ត ក្រុងសាម៉ីដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣០:** សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពី គណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១:** ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង សហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិក មហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២:** លក្ខន្តិកៈសហគមន៍នេសាទនេះ បានអនុម័តដោយអង្គប្រជុំរបស់គណៈកម្មការសហព័ន្ធ សហគមន៍នេសាទចំប៉ី លើកដំបូងនៅថ្ងៃទី ១៧-១៨ ខែ មិថុនា ឆ្នាំ២០០៦ និងចូលជាធរមាននៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានចុះហត្ថលេខារបស់ គណៈកម្មការ សហព័ន្ធ សហគមន៍នេសាទចំប៉ី។

ថ្ងៃទី ០៤ ខែ ០៥ ឆ្នាំ ២០០៨

**បានឃើញនិងឯកភាព**

**មេឃុំចំប៉ី**

ហង់ ថៃ

**ប្រធានគណៈកម្មការ សហព័ន្ធ**

**សហគមន៍នេសាទចំប៉ី**

ហែម ឆឿន

ថ្ងៃទី ខែ ឆ្នាំ ២០០៨

**បានឃើញ និងឯកភាព**

**ខណ្ឌរដ្ឋបាលជលផលតាកែវ**

ថ្ងៃទី ៤ ខែ ០៦ ឆ្នាំ ២០០៨

**បានឃើញ និងឯកភាព**

**អភិបាលស្រុកបាទី**

ឡាយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៛៚៚

# ៥-ប្លង់បញ្ជាក់ផ្ទៃក្នុងសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ចំប៊ី |
| ភូមិ | ៖ | ម្កាក់(ទំនប់សំពោច) |
| ឃុំ | ៖ | ចំប៊ី |
| ស្រុក | ៖ | បាទី |
| ខេត្ត | ៖ | តាកែវ |

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ **សហព័ន្ធសហគមន៍នេសាទចំប៉ី** សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម÷

**ប្រការ ១៖** គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្តាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២៖** គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ច ធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀត ត្រូវសងទៅតាមទំហំនៃការខូចខាតជាក់ស្តែងតាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច។

- ចំពោះគណៈកម្មការសហគមន៍នេសាទ ត្រូវសងតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបានត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣៖** សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ដង ជាប់គ្នា ដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤៖** សិទ្ធិដាក់ទណ្ឌកម្ម÷

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ចំពោះនេសាទលើសទំហំ ចំនួន ខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**ខ-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ

- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

**ប្រការ ៥:** សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈ ឧបករណ៍នេសាទដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦:**សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុង**រដូវបើកនេសាទ**ចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា រហូតដល់ ថ្ងៃទី ៣០ ខែមិថុនា ដូចមានចែង ខាងក្រោម ÷

**ក. រដូវបើកនេសាទ**

- មងប្រវែងមិនលើសពី ៣០០ ម៉ែត្រ
- អួនប្រវែងមិនលើសពី ៤០ ម៉ែត្រ
- អួនព្រយុងប្រវែងមិនលើសពី ៥០ ម៉ែត្រ
- អញ្ចូងប្រវែងមិនលើសពី ៥ ម៉ែត្រ
- អញ្ចូងរុញប្រវែងមិនលើសពី ៣ ម៉ែត្រ
- ថ្នងទំហំមិនលើសពី ៣ ម៉ែត្រ
- សំណាញ់ប្រវែងមិនលើសពី ៥ ម៉ែត្រ
- ឈ្នក់ចំនួនមិនលើសពី ៣ x ៣ ម៉ែត្រ
- លាន់ចំនួនមិនលើសពី ១០ គ្រឿង
- ឡើចំនួនមិនលើសពី ២០ គ្រឿង
- ទ្រូចំនួនមិនលើសពី ៥ គ្រឿង
- សៃត្រី,កំពិសចំនួនមិនលើសពី ៥ គ្រឿង
- សៃនុយចំនួនមិនលើសពី ៣០ គ្រឿង
- ប៉ោងចំនួនមិនលើសពី ៥ គ្រឿង
- លបត្រីរស់ចំនួនមិនលើសពី ១០ គ្រឿង
- សន្ទូចរនងចំនួនមិនលើសពី ៥០០ ផ្លែ
- បង្កៃចំនួនមិនលើសពី ២០០ ផ្លែ

**ខ.រដូវបិទនេសាទចាប់ពីថ្ងៃទី ០១ ខែ កក្កដា រហូតដល់ ថ្ងៃទី ៣១ ខែ តុលា** ដូចមានចែង ខាងក្រោម ÷

- មងប្រវែងមិនលើសពី ១០០ ម៉ែត្រ
- អញ្ចូងរុញប្រវែងមិនលើសពី ២ម៉ែត្រ
- ថ្នងទំហំមិនលើសពី ៣ ម៉ែត្រ
- សំណាញ់ប្រវែងមិនលើសពី ៥ ម៉ែត្រ
- លាន់ចំនួនមិនលើសពី ៥ គ្រឿង
- ឡើចំនួនមិនលើសពី ២០ គ្រឿង

- ទ្រូចំនួនមិនលើសពី ៣ គ្រឿង
- សៃត្រី,កំពិសចំនួនមិនលើសពី ៣គ្រឿង
- សៃនុយចំនួនមិនលើសពី ១០ គ្រឿង
- ប៉ោងចំនួនមិនលើសពី ៣ គ្រឿង
- លបត្រីរស់ចំនួនមិនលើសពី ៥ គ្រឿង
- សន្ទូចរនងចំនួនមិនលើសពី ៣០០ ផ្លែ
- បង្កៃចំនួនមិនលើសពី ១០០ ផ្លែ

**ប្រការ ៧:** សមាជិកសហគមន៍នេសាទដែល÷

-ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត

-មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ

-ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្កាថ្ម ឬស្មៅសមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាម ច្បាប់ស្តីពីជលផល

-ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច

-អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការ នេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅ រដ្ឋបាលជលផលមានសមត្ថកិច្ចដោះស្រាយតាមច្បាប់។

**ប្រការ៨:** បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ បានអនុម័តដោយអង្គប្រជុំរបស់គណៈកម្មការសហព័ន្ធ សហគមន៍នេសាទចំប៉ី លើកដំបូងនៅថ្ងៃទី ១៧-១៨ ខែ មិថុនា ឆ្នាំ២០០៦ និងចូលជាធរមាននៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៦ ដោយមានចុះហត្ថលេខារបស់ គណៈកម្មការ សហព័ន្ធ សហគមន៍នេសាទចំប៉ី។

ថ្ងៃទី ខែ ឆ្នាំ ២០០៨

**បានឃើញ និងឯកភាព**

**មេឃុំចំប៉ី**

**ប្រធានគណៈកម្មការ សហព័ន្ធ**

**សហគមន៍នេសាទចំប៉ី**

**ហែម គឿន**

ថ្ងៃទី ខែ ឆ្នាំ ២០០

**បានឃើញ និងឯកភាព**

**ខណ្ឌរដ្ឋបាលជលផលតាកែវ**

ថ្ងៃទី ខែ ឆ្នាំ ២០០

**បានឃើញ និងឯកភាព**

**អភិបាលស្រុកបាទី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិសាសនាព្រះមហាក្សត្រ

# ៦-សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ ៖ ចំប៉ី

ភូមិ ៖ ម្កាក់(ទំនប់សំពោច)

ឃុំ ៖ ចំប៉ី

ស្រុក ៖ បាទី

ខេត្ត ៖ តាកែវ

# សេចក្តីថ្លែងការណ៍

យើងខ្ញុំគណៈកម្មការសហព័ន្ធ សហគមន៍នេសាទចំប៉ី ដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦ ក្រោមការឧបត្ថម្ភបច្ចេកទេសដោយខណ្ឌរដ្ឋបាលជលផលតាកែវ ក្នុងកិច្ចសហការជាមួយគម្រោង MRC/ FMG, IDRC និងអង្គការ UNDP ។

យើងខ្ញុំសូមគោរពជម្រាបលោកនាយខណ្ឌរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ បានកើតឡើងបន្ទាប់ពីមានភាពអណាធិបតេយ្យនៃការនេសាទខុសច្បាប់ និងទំនាស់ដែននេសាទ ធ្វើឱ្យប្រជាពលរដ្ឋក្នុងឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ បានឯកភាពគ្នាធ្វើសំណើសុំបង្កើតសហគមន៍នេសាទចំប៉ីនេះឡើង និងស្របតាមគោលនយោបាយកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាលនៅចុងឆ្នាំ ២០០០។ ក្នុងគោលបំណង ការពារ គ្រប់គ្រង ប្រើប្រាស់ អភិរក្ស អភិវឌ្ឍន៍ ធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីចូលរួមកាត់ បន្ថយភាពក្រីក្រ ក្នុងសហគមន៍មូលដ្ឋាន ។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទក្នុងឆ្នាំ ២០០៦ រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗ ជាច្រើនដូចជា មានដាក់ស្លាកសញ្ញាផ្សព្វផ្សាយអំពីសារៈសំខាន់នៃធនធានជលផល ដើម្បីបង្កើនការចូលរួមពីប្រជាពលរដ្ឋក្នុងការគ្រប់គ្រងធនធានជលផល ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការងារយាមល្បាតបង្ក្រាបបទល្មើស រាយការណ៍ពីសកម្មភាពផ្សេងៗទៅស្ថាប័នជំនាញ និងក្រុមប្រឹក្សាសង្កាត់ បណ្តុះបណ្តាលការសរសេរសំណើសាមញ្ញខ្លីៗ សរសេររបាយការណ៍ និងសរសេរកំណត់ហេតុ ជំនាញសម្របសម្រួលរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ ផែនទីកន្លែងនេសាទសហគមន៍ កន្លែងអភិរក្សត្រីមេពូជ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សេចក្តីថ្លែងការណ៍ និងការអភិវឌ្ឍន៍សហគមន៍នេសាទ ។ល។ ទន្ទឹមនឹងនេះសហព័ន្ធសហគមន៍នេសាទយើងខ្ញុំ បានរៀបចំរួចរាល់នូវឯកសារ សម្រាប់បង្កើតសហគមន៍នេសាទដូចមានចែងក្នុងមាត្រា ៧ ជំពូកទី ២ នៃអនុក្រឹត្យស្តីពី ការគ្រប់គ្រង សហគមន៍នេសាទដែលរួមមាន បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ នេសាទ និង ផែនទីកន្លែងនេសាទសហគមន៍ ។

ដោយផ្អែកលើសមិទ្ធិផល ដូចបានរៀបរាប់ខាងលើ និងការសម្រេចរបស់មហាសន្និបាត ដែលបានប្រារព្ធធ្វើនៅ ថ្ងៃទី ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៦ យើងខ្ញុំគណៈកម្មការ តំណាងឱ្យសហព័ន្ធ សហគមន៍នេសាទចំប៉ី សូមគោរពជូនលោកនាយខណ្ឌរដ្ឋបាលជលផលតាកែវ នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលមានភ្ជាប់មកជាមួយបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ដើម្បីពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហព័ន្ធ សហគមន៍នេសាទចំប៉ី សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដោយគោរពទៅតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងច្បាប់លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងវិស័យជលផល ។

បើសិនជាយើងខ្ញុំបានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

អាស្រ័យហេតុនេះ សូមលោកនាយខណ្ឌរដ្ឋបាលជលផលមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅភូមិម្កាក់, ថ្ងៃទី១៨....ខែ១២...ឆ្នាំ ២០០៩

**ប្រធានគណៈកម្មការសហគមន៍នេសាទចំប៉ី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ៧-ឯកសារផ្សេងៗ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | ចំប៉ី |
| ភូមិ | ៖ | ម្កាក់(ទំនប់សំពោច) |
| ឃុំ | ៖ | ចំប៉ី |
| ស្រុក | ៖ | បាទី |
| ខេត្ត | ៖ | តាកែវ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលតាកែវ**

**កម្មវត្ថុ :** សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សហព័ន្ធ **ចំប៉ី** ។

**យោង :** - អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ។

- សេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទភូមិព្រៃកស្វាយ ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៦ ។

**លិខិតភ្ជាប់ :** កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សហព័ន្ធ ចំប៉ី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមេត្តាជ្រាបថា សហព័ន្ធសហគមន៍នេសាទចំប៉ី បានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឃុំចំប៉ី ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលតាកែវ។ សហព័ន្ធសហគមន៍នេសាទ មានទីតាំងស្ថិតនៅភូមិម្កាក់(ទំនប់សំពោច) ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ មានផ្ទៃទំហំ **៤៦១** ហិចតា ដឹកនាំដោយគណៈកម្មការសហព័ន្ធសហគមន៍នេសាទចំនួន **០៧ រូប** និងគណៈកម្មការសហគមន៍នេសាទប្រាំភូមិចំនួន **៣៥ រូប** មានសមាជិកសរុបចំនួន **៣៨០ រូប** ស្រីចំនួន **២១៦ រូប** បន្ទាប់ពីបានបង្កើតរួចមក សហព័ន្ធ សហគមន៍នេសាទចំប៉ី បានដំណើរការការងារយ៉ាងសស្រាក់សស្រាំ ដោយមានការចូលរួមឧបត្ថម្ភ គាំទ្រនាយកដ្ឋានកិច្ចឡូនី សហគមន៍នេសាទ នៃរដ្ឋបាលជលផល ស្ថាប័នជំនាញ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាសង្កាត់ និងអង្គការនានា។ ព្រមជាមួយនោះ គណៈកម្មការសហគមន៍នេសាទបានរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ ផែនទី និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេច ហើយនឹងគ្រោងរៀបចំកម្មវិធីចុះកិច្ចព្រមព្រៀងសហគមន៍នេសាទ ជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលតាកែវ ដែលនឹងប្រព្រឹត្ត ធ្វើឡើងនាថ្ងៃទី ២៦ ខែ មថុនា ឆ្នាំ ២០០៩ នៅភូមិម្កាក់(ទំនប់សំពោច) ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ ដោយមានការចូលរួមពីសមាជិក សមាជិការសហគមន៍ នេសាទ អាជ្ញាធរមូលដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាសង្កាត់ជាសាក្សី ។

សូមភ្ជាប់មកជាមួយនូវ :

១- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

២- ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០.០០០

៣- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ

៤- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

៥- សេចក្តីថ្លែងការណ៍ នៃការបង្កើតសហគមន៍នេសាទ ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅភូមិម្កាក់, ថ្ងៃទី16 ខែ12 ឆ្នាំ២០09

**ប្រធានគណៈកម្មការ**

**សហព័ន្ធសហគមន៍នេសាទចំប៉ី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលជលផល**
**អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ**
**ខណ្ឌរដ្ឋបាលជលផលតាកែវ**
លេខ ២៨១/០៩ ខរជផតក

**នាយខណ្ឌរដ្ឋបាលជលផលតាកែវ**
**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**តាមរយៈ** : -លោកនាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ ។
-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

**កម្មវត្ថុ** : សំណើសុំចុះបញ្ជី និងចុះហត្ថលេខាលើផែនទីកន្លែងនេសាទសហគមន៍ របស់សហគមន៍នេសាទ ចំនួន០២ ស្ថិតនៅក្នុងខេត្តតាកែវ ។

**យោង** : -អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។
-ប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។

**ជូនភ្ជាប់** : - កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចំនួន ០២ សហគមន៍ ចំនួន ០២ ច្បាប់
- ផែនទីមាត្រដ្ឋាន ១/៥០ ០០០ របស់សហគមន៍នេសាទចំនួន ០២ ចំនួន ០២ ច្បាប់
-បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទចំនួន១៦សហគមន៍ ចំនួន ១៦ច្បាប់
-សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងនៃការបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល ដោយមានការអះអាងអំពីការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព ចំនួន ០២ សហគមន៍ ចំនួន ០២ ច្បាប់
- តារាងស្តីពីឈ្មោះសហគមន៍នេសាទដែលស្នើសុំចុះបញ្ជី ចំនួន ០១ ច្បាប់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តា ជ្រាបថា ចាប់តាំងពីរាជរដ្ឋាភិបាលបានធ្វើការកែទម្រង់វិស័យជលផលមក ខណ្ឌរដ្ឋបាលជលផលតាកែវបានខិតខំជម្រុញដំណើរការរៀបចំសហគមន៍នេសាទទូទាំងខេត្តតាកែវ បានយ៉ាងទូលំទូលាយដោយមានការចូលរួម យ៉ាងផុលផុសពីសំណាក់ប្រជាពលរដ្ឋ មូលដ្ឋានមានការគាំទ្រ និងកិច្ចសហការល្អពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងមានការឧបត្ថម្ភពីអង្គការក្រៅ

អាសយដ្ឋាន ភូមិ ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ទូរស័ព្ទ-ទូរសារលេខ: (៨៥៥) (០៣២) ៩៣១ ៤៩៨
Address : Phum 2, Sankat Roka Khnong, Krong Dorn Keo, Takeo Province. Phone-Fax: (855) (032) 931 498

រដ្ឋាភិបាលនានាដែលធ្វើឱ្យដំណើរការរៀបចំសហគមន៍នេសាទនៅក្នុងខេត្តតាកែវទទួលបានលទ្ធផលល្អគួរជាទី មោទនៈ ។

ដូច្នេះ ខ្ញុំបាទសូមអនុញ្ញាតឯកឧត្តមរដ្ឋមន្ត្រី ពិនិត្យចុះបញ្ជីនូវសហគមន៍នេសាទចំនួន ០២ របស់ខេត្តតាកែវ ដើម្បីឱ្យមានការទទួលស្គាល់ជាផ្លូវការ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។ ៚

តាកែវ, ថ្ងៃទី ១២ ខែ ៥ ឆ្នាំ ២០០៩

**នាយខណ្ឌរដ្ឋបាលជលផលតាកែវ**

**អ៊ឹ_សុផាន**

លេខៈ ២៤០ អរ.ច

បានឃើញ និង គោរពជូន

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល**

**" ដើម្បីពិនិត្យដោយអនុគ្រោះ"**

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ៥ ឆ្នាំ ២០០៩

**នាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ**

**សុខ_ហុង**

លេខៈ....................ជផ

បានឃើញ និង គោរពជូន

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**" ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"**

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

## តារាងស្តីពីឈ្មោះសហគមន៍នេសាទក្នុងខេត្តតាកែវស្នើចុះបញ្ជី

| ល.រ | ឈ្មោះសហគមន៍នេសាទ | ទីតាំង | | | ចំនួនគណៈកម្មការសហគមន៍នេសាទ | ចំនួនសមាជិកសហគមន៍នេសាទ | ផ្ទៃដី (ហ.ត) | Projection : UTM, Spheroid : Everest 1830, Datum : Indian 1960, Zone : 48 N | |
|---|---|---|---|---|---|---|---|---|---|
| | | ភូមិ | ឃុំ/ សង្កាត់ | ស្រុក/ ក្រុង | | | | UTM.(X, Y) | UTM.(X, Y) |
| ១ | ពត់សរ | ពត់សរ, ត្រពាំងត្រាវ, ក្រាំងពោធិ៍,ខ្លាកូន, គ្រួច, ព្រៃស្វា, កណ្តោល, ចំបក់, ឃ្លាំងសម្បត្ត, ខ្វាន់មាស,តាំងឫស្សី | ពត់សរ | បាទី | ១១ នាក់ | ៧៤៤ នាក់ ( ស្រី ៣៤២ នាក់) | ១.២២២ | A.( 490743, 1247115)<br>B.(490964, 1247745)<br>C.(489944, 1249026)<br>D.(489637, 1243191)<br>E.(489401, 1249063)<br>F.(489447, 1249396)<br>G.(489557, 1249382)<br>H.(489584, 1249532)<br>I.(490253, 1249573)<br>J.(490376, 1249451)<br>K.(490731, 1249410)<br>L.(490813, 1248877)<br>M.(491032, 1248863)<br>N.(491291, 1249532)<br>O.(492397, 1249451)<br>P.(492370, 1250721)<br>Q.(490472, 1253342)<br>R.(489953, 1253370)<br>S.(488696, 1254107) | T.(488150, 1254025)<br>U.(488152, 1254148)<br>V.(488496, 1254380)<br>W.(488649, 1254332)<br>X.(488997, 1254380)<br>Y.(489483, 1253986)<br>Z.(490659, 1253784)<br>AB.(491183, 1253200)<br>AC.(491770, 1252469)<br>AD.(491616, 1252325)<br>AE.(492549, 1251669)<br>AF.(493213, 1251960)<br>AG.(493717, 1251981)<br>AH.(493836, 1248673)<br>AI.(493544, 1247675)<br>AJ.(491452, 1247771)<br>AK.(492069, 1247197)<br>AL.(490977, 1246938) |
| ២ | ចំប៉ី | ជើងលោង, ម្កាក់, ព្រៃមូល,មឿងប្រចិន, ជើមដូង | ចំប៉ី | បាទី | ០៧ នាក់ | ៣៨០ នាក់ ( ស្រី ២១៦ នាក់) | ៤៦១ | A.(489101, 1247711)<br>B.(488816, 1247810)<br>C.(488984, 1248820)<br>D.(489204, 1248998)<br>E.(489635, 1249122)<br>F.(489946, 1249017)<br>G.(490965, 1247750)<br>H.(490743, 1247119)<br>I,(490305, 1246608)<br>J.(490056, 1246239) | K.(488719, 1244541)<br>L.(487278, 1244610)<br>M.(487278, 1245253)<br>N.(489002, 1246008)<br>O.(490005, 1246668)<br>P.(490296, 1247251)<br>Q.(490416, 1247791)<br>R.(489850, 1248486)<br>S.(489602, 1248426)<br>T.(489362, 1248014) |

តាកែវ, ថ្ងៃទី...១៦...ខែ...[illegible]...ឆ្នាំ ២០០៩

**នាយខណ្ឌរដ្ឋបាលជលផលតាកែវ**